# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ០៥ រប-៩៧

## សារាចរ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ជូនចំពោះ**

**លោកចៅក្រម ទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីដីកាសម្រេចតាមពាក្យសុំ ។

ដោយសភាពការណ៍ក្នុងប្រទេសមានការវិវត្តន៍ឆាប់រហ័ស បញ្ហាគ្រោះថ្នាក់ជាបន្ទាន់ផ្សេងៗអាចនឹងកើតមានឡើងហើយធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ។

ដូចនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សូមធ្វើការណែនាំដូចខាងក្រោម ៖

អំណើះតទៅចៅក្រមអាចចេញដីកាសម្រេចតាមពាក្យសុំទេឱ្យភាគីម្ខាង ដែលមានការប្រញាប់ឬត្រូវការជាបន្ទាន់បំផុត ដើម្បីការពារសេចក្តីអន្តរាយដល់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួនបាន ។

រីឯភាគីដែលមិនសុខចិត្តនឹងដីកានេះ ដោយយល់ឃើញថាដីកានេះធ្វើអោយប៉ះពាល់ឬខូចប្រយោជន៍របស់ខ្លួន ភាគីនោះអាចប្តឹងត្រូវទៅចៅក្រមដែលចេញដីកានេះ សុំឱ្យពិនិត្យនិងជំនុំជម្រះលើដីកានេះបាន។ ភាគីនេះអាចប្តឹងតវ៉ានឹងដីការនេះបានក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរបំផុត គិតចាប់ពីថ្ងៃឱ្យដំណឹងពីដីកានេះ ។

ក្នុងករណីមានពាក្យប្តឹងតវ៉ាអំពីដីកានេះ ចៅក្រមត្រូវសម្រេចជាកិច្ចការប្រញាប់ ។

ការចេញដីកាសម្រេចតាមពាក្យសុំនេះ មិនត្រូវឱ្យប៉ះពាល់ ឬខូចខាតដល់ផលប្រយោជន៍របស់ជនដទៃក្រៅពីគូភាគីឡើយ ។

ពាក្យសុំនិងដីកាសម្រេចតាមពាក្យសុំនេះ ត្រូវតម្កល់ទុកនៅមន្ទីរក្រឡាបញ្ជី ។ ក្រឡាបញ្ជីត្រូវចម្លងដីកាសម្រេចតាមពាក្យសុំនេះមួយច្បាប់ ឱ្យភាគីដែលសុំអោយចេញដីកានេះ ។

ដើម្បីធានាការពារដល់ផលប្រយោជន៍របស់ភាគីទាំងអស់ ខ្ញុំសុំលោកចៅក្រមទាំងអស់យកចិត្តទុកដាក់អនុវត្តស្មារតីនៃសារាចរនេះ អោយបានត្រឹមត្រូវជាទីបំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្នួន**